**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * * * * * * * * *

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ រវាង

# ក្រុមហ៊ុន ស៊ីផេក ហ្គាមិន (ខេមបូឌា) ឯ.ក

# ជាមួយប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១:00 រសៀល នៅក្នុងរោងចក្រ **ស៊ីផេក ហ្គាមិន (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក&ប្រធានក្រុម។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិកទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកកម្មករមួយចំនួន។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន៣១ នាក់ (ស្រី១៩ នាក់) រយៈពេល ៣១ ថ្ងៃ ដែលគិតចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៤ ដោយរក្សាតួនាទី ភារកិច្ច និងអត្ថប្រយោជន៍កម្មករពេលចូលធ្វើការវិញនៅដដែល ហើយកំឡុងពេលព្យួរកិច្ចសន្យានេះកម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវទឹកប្រាក់ឧបត្ថម្ភក្នុងមួយខែ ៣០ ដុល្លារសហរដ្ឋអាមេរិច។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនបងប្អូនកម្មករ នៅមុនថ្ងៃឈប់សម្រាកព្យួរដែលត្រូវនឹងថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៣។ អង្គប្រជុំនេះបានបញ្ចប់នៅវេលាម៉ោង ២ និង ០៥ នាទីរសៀល នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសុក្រ ១០ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ភ្នំពេញ, ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២៣

**ប្រតិភូបុគ្គលិក និងប្រធានក្រុម** **នាយកក្រុមហ៊ុន**

ក្រុមហ៊ុន
ស៊ីផេកហ្គាមិន(ខេមបូឌា)ឯ.ក
CPAK GARMENT (CAMBODIA) CO.,LTD
KINGDOM OF CAMBODIA